ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

## កម្ពុជាត្រៀមស្វាគមន៍ទស្សនកិច្ចរបស់ប្រធានាធិបតីសាធារណរដ្ឋកូរ៉េ

******

ក្នុងជំនួបសម្តែងការគួរសមរបស់ឯកឧត្តម Yoon Soon-Gu អនុរដ្ឋមន្ត្រីការបរទេសទទួលបន្ទុកកិច្ចការនយោបាយរបស់សាធារណរដ្ឋកូរ៉េ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកឧត្តម **ប្រាក់ សុខុន** ទេស-រដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានរំលឹកពីការខិតខំផ្ទាល់របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងការជម្នះពុះពារឈានទៅបង្កើតឡើងនូវទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ ក្នុងឆ្នាំ១៩៩៧ និងបានសម្តែងក្តីរីករាយចំពោះការរីកចម្រើនយ៉ាងល្អប្រសើរនៃទំនាក់ទំនងទាំងក្នុងក្របខ័ណ្ឌទ្វេភាគី អាស៊ាន-កូរ៉េ និងមេគង្គ-កូរ៉េ។ **ឯកឧត្តម** ក៏បានថ្លែងអំណរគុណចំពោះជំនួយឧបត្ថម្ភគ្រប់បែបយ៉ាងរបស់កូរ៉េចំពោះកម្ពុជា។

**ឯកឧត្តមអនុរដ្ឋមន្ត្រី** បានពាំនាំការផ្តាំផ្ញើសួរសុខទុក្ខរបស់រដ្ឋមន្ត្រីការបរទេសកូរ៉េជូនចំពោះ**ឯកឧត្តមទេសរដ្ឋមន្ត្រី** និងបានកត់សម្គាល់ដោយការពេញចិត្តចំពោះលទ្ធផលប្រកបដោយផ្លែផ្កាក្នុងទំនាក់ទំនងរវាងប្រទេសទាំងពីរ។ **ឯកឧត្តម** ក៏បានអះអាងពីបំណងរបស់រដ្ឋាភិបាលកូរ៉េបន្តជំរុញកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យជាមួយកម្ពុជា ពិសេសលើការផ្លាស់ប្តូរពាណិជ្ជកម្ម និងវិនិយោគ។ **គណៈប្រតិភូ** ក៏បានជម្រាប ឯកឧត្តមទេសរដ្ឋមន្ត្រីពីបំណងរបស់វិនិយោគិនកូរ៉េ បន្តដំណើរការគំរោងសាងសង់អាគារខុនដូរ៤២ជាន់ និងគំរោងនៅកាំកូស៊ីតធី ដែលបានផ្អាកដំណើរការក្នុងរយៈកាលកន្លងមក។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានធ្វើការកត់សម្គាល់ពីការថ្លែងប្រកាសរបស់ឯកឧត្តមប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ អំពីបំណងបំពេញទស្សនកិច្ចនៅតាមបណ្តាប្រទេសអាស៊ាន និងបានគូសបញ្ជាក់ថាកម្ពុជាត្រៀមស្វាគមន៍ដំណើរទស្សនកិច្ចនេះ។

ឆ្លើយតបនឹងការលើកឡើងរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី អំពីសំណើរបស់កម្ពុជាឲ្យកូរ៉េសាងសង់ស្ពានមិត្តភាពកម្ពុជា-កូរ៉េ ភ្ជាប់ពីជ្រោយចង្វារទៅស្វាយជ្រុំ (អរិយក្សត្រយ៍) **ឯកឧត្តមអនុរដ្ឋមន្ត្រី** បានគូសបញ្ជាក់ថាបច្ចុប្បន្នកូរ៉េកំពុងសិក្សាយ៉ាងហ្មត់ចត់ និងដោយយកចិត្តទុកដាក់លើសំណើនេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានលើកឡើងពីការរីកចម្រើនគួរឲ្យកត់សំគាល់ក្នុងទំនាក់ទំនងផ្នែកទេស-ចរណ៍រវាងប្រទេសទាំងពីរ និងពីសារៈប្រយោជន៍នៃការបង្កើតឲ្យមានជើងហោះហើរត្រង់កម្ពុជា-កូរ៉េ ដែលមិនត្រឹមតែរួមចំណែកសម្រួលដល់ទំនាក់ទំនងទេសចរណ៍ និងសេដ្ឋកិច្ចនៃប្រទេសទាំងពីរ តែក៏ជួយសម្រួលផងដែរដល់ការផ្សាភ្ជាប់កម្ពុជាជាមួយពិភពលោក។

នៅក្នុងឱកាសនេះដែរ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានស្នើឲ្យកូរ៉េរៀបចំកិច្ចប្រជុំលើកទី៤ នៃគណៈកម្មាធិការចំរុះកម្ពុជា-កូរ៉េ ដើម្បីធ្វើការពិភាក្សាអំពីកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងប្រទេសទាំងពីរ។

ឆ្លើយតបនឹងការលើកឡើងរបស់ឯកឧត្តមអនុរដ្ឋមន្ត្រីអំពីបំណងរបស់កូរ៉េចង់រៀបចំឲ្យមានកិច្ចប្រជុំកំពូលពិសេសអាស៊ាន-កូរ៉េ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា ក្នុងនាមជាប្រទេសសម្របសម្រួល

សម្រាប់ទំនាក់ទំនងអាស៊ាន-កូរ៉េ កម្ពុជាគាំទ្រគំនិតផ្តួចផ្តើមនេះ ហើយនឹងខិតខំសម្របសម្រួលជាមួយប្រទេសសមាជិកអាស៊ានផ្សេងទៀត។ **ឯកឧត្តមអនុរដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះការរួមចំណែកដ៏សកម្មរបស់កម្ពុជាក្នុងឋានៈជាប្រទេសសម្របសម្រួលសម្រាប់ទំនាក់ទំនងអាស៊ាន-កូរ៉េ ក្នុងរយៈកាលកន្លងមកនេះ។

នៅក្នុងជំនួបនេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** និង**ឯកឧត្តមអនុរដ្ឋមន្ត្រី** បានពិភាក្សាផ្លាស់ប្តូរយោបល់គ្នាអំពីលទ្ធភាពនៃការតម្លើងទំនាក់ទំនងមេគង្គ-កូរ៉េ ពីកម្រិតកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេស ទៅកិច្ចប្រជុំ កំពូល។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

ថ្ងៃសុក្រ ១ រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ភ្នំពេញ, ថ្ងៃទី០២ ខែ មីនា ឆ្នាំ២០១៨